ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៙៙៙៙៙៙៙

តុលាការកំពូល

-------

សំណុំរឿងព្រហ្មទណ្ឌ

លេខ : ៦៣

ចុះថ្ងៃទី ០៤-៩-២០០១

សាលដីកា

លេខ : ១៦

ចុះថ្ងៃទី ១៣-០២-២០០២

តាងនាមប្រជារាស្ត្រខ្មែរ

តុ លា កា រ កំ ពូ ល

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០០២ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះ ដូចតទៅ :

១- ឯកឧត្តម ឃឹម ប៉ុណ្ណ ប្រធាន
២- លោក ឃឹម ស៊ីផល ចៅក្រម
៣- លោក ទេវ៉ុល អួន ចៅក្រម
៤- លោក ស៊ិន ឌឹម ចៅក្រម
៥- លោក ប្រាក់ គីមសាន ចៅក្រមរបាយការណ៍
៦- លោក យស់ សុខេវីន ចៅក្រម
៧- លោក ជីវ កេង ចៅក្រម
៨- លោក ម៉ែន សារឿន ចៅក្រម
៩- លោក សោម សិរីវុឌ្ឍ ចៅក្រម

លោក ប៉ុល វណ្ណា ក្រឡាបញ្ជី

តំណាងអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខ លេខ ៣៥ ចុះថ្ងៃទី ១៥-៥-២០០១ របស់អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ដែលប្តឹងពីសាលដីកាព្រហ្មទណ្ឌលេខ ១០០ ចុះថ្ងៃទី ០៦-៤-២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី២ នៃសេចក្តីសំរេច និង សំណុំរឿងព្រហ្មទណ្ឌលេខ ៦៣ ចុះថ្ងៃទី ០៤-៩-២០០១ របស់តុលាការកំពូល ។

ពីបទ : សមគំនិតក្នុងបទល្មើសធ្វើមនុស្សឃាតដោយចេតនាគិតទុកជាមុន ប្រព្រឹត្តនៅភ្នំពេញ កាលពីថ្ងៃទី ៦៤-១១ ១៩៩៧ តាមបញ្ញត្តិមាត្រា ៦៩ និង ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

១- ជនជាប់ចោទឈ្មោះ ពេង សារឿន ហៅ ទឹថ ស្រ៊ុន "ចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៥២ឆ្នាំ ជាតិខ្មែរ មុខរបរនាំស្រីទៅលក់នៅប្រទេសវៀតណាម ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៤០០ ផ្លូវព្រះសីហនុ សង្កាត់ទួលស្វាយព្រៃ២ ខ័ណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ គិច សៀង ម្តាយឈ្មោះ ម៉ែន លាង ប្រពន្ធឈ្មោះ ដួន គីមអួន មានកូន ០៣នាក់ ទោសពីមុនគ្មាន នៅក្រៅឃុំ ។

.. មេធាវី លោក ខៀវ សុផល

២-ជនជាប់ចោទឈ្មោះ ជា សុខចេង ហៅ មុំ ស៊ីណាត "ចុងបណ្ដឹងសាធុក្ខ" ភេទប្រុស អាយុ៣១ឆ្នាំ ជាតិខ្មែរ កើតនៅភូមិ-ឃុំ ជប់ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម មុខរបរនគរបាលតម្រួតការពារ មានទីលំនៅមុនពេលចាប់ខ្លួន ក្រុមទី១៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ក្រុងភ្នំពេញ ឪពុកឈ្មោះ មុំ នួន "រ" ម្ដាយឈ្មោះ សាន់ នី "រ" ប្រពន្ធឈ្មោះ ហ៊ិន សំអាង មានកូន០២នាក់ ទោសពីមុនគ្មាន នៅក្នុងឃុំ ។ .. មេធាវី លោក ខៀវ សុផល ។

-ត្រូវចោទពីបទ : ធ្វើមនុស្សឃាតដោយចេតនាគិតទុកជាមុន ប្រព្រឹត្តនៅ ក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤-១១ ១៩៩៧ តាមបញ្ញត្តិមាត្រា ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៣-ជនជាប់ចោទឈ្មោះ ប៊ិន បញ្ញាធី ភេទប្រុស អាយុ ៣៤ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃ ផ្ទះលេខថ្មី សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ប៊ិន ហុង "ស" ម្ដាយឈ្មោះ អៀក យុត "រ" ប្រពន្ធឈ្មោះ វ៉ាន់ ផល មានកូន ០១នាក់ ។

៤-ជនជាប់ចោទឈ្មោះ ទស់ ស្រៀវ ហៅ ជ្រា ភេទប្រុស អាយុ ៣០ឆ្នាំ ជាតិខ្មែរ ទីលំនៅមុនពេលចាប់ខ្លួន ភូមិសន្សំកុសល សង្កាត់បឹងទំពុន ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ ទស់ ជ្រើយ "ស" ម្ដាយឈ្មោះ ស្រី ទឡ្ហុង "រ" ប្រពន្ធឈ្មោះ អ៊ិន ស៊ីថា មានកូន០៣នាក់ នៅក្នុងឃុំ ចាប់ខ្លួនថ្ងៃទី ១៥-៥-១៩៩៩ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ស្រី ម៉េងឡុង ជាប្រពន្ធរបស់ជនរងគ្រោះ មានទីលំនៅសព្វថ្ងៃ ផ្ទះលេខ ១៤៤ ផ្លូវមន្ទីរពេទ្យ សង្កាត់មានជ័យ ខណ្ឌមានជ័យ ក្រុងភ្នំពេញ ។

-ឯកឧត្តម អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ "ម្ចាស់បណ្ដឹងសាធុក្ខ"

-តាមរបាយការណ៍ របស់នគរបាលប៉ុស្តិ៍ ទួលស្វាយព្រៃ ចុះថ្ងៃទី ១៤-១១ ១៩៩៧ ថា : កាលពីថ្ងៃទី ១៤-១១ ១៩៩៧ វេលាម៉ោង ១៥ និង ៣០នាទី មានករណីបាញ់សម្លាប់មនុស្សម្នាក់បណ្ដាលឲ្យស្លាប់កើតឡើងនៅចំណុចមុខវិទ្យាល័យនិកសិទ្ធិសាលសុខ ជនរងគ្រោះឈ្មោះ ម៉ី មឿន ដែលកំពុងឈរ និយាយ ទូរស័ព្ទ ស្រាប់តែមានជនល្មើសពីរនាក់ ស្លៀកពាក់ស៊ីវិល ប្រដាប់ដោយអាវុធខ្លី មួយដើមម៉ាកកា៥៩ ជិះម៉ូតូមួយគ្រឿង ម៉ាក់ឌ្រីម៉ាល់ ពណ៌ក្រហមខ្មុបគ្នា ហើយមានម្នាក់ចុះមកបាញ់ជនរងគ្រោះពីក្រោយចំនួន ៤ គ្រាប់បណ្ដាលអោយជនរងគ្រោះស្លាប់នៅនឹងកន្លែងចំណែកជនល្មើសគេចខ្លួនបាត់ ។

-បានឃើញសេចក្ដីសន្និដ្ឋាន របស់តំណាងអយ្យការ អម តុលាការក្រុងភ្នំពេញបានសំរេច :

១-ចោទប្រកាន់លើឈ្មោះ ពេង សារឿន ហៅ ថៃ ស៊្រុន និង ឈ្មោះ ជា សុខចេង ហៅ មុំ ស៊ីណាត ភេទប្រុស អាយុ ៣១ឆ្នាំ ពីបទសមគំនិតក្នុងបទធ្វើមនុស្សឃាតដោយចេតនាគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤-១១ ១៩៩៧ ។ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្ដន្ទាទោសតាមមាត្រាទី ៦៩ , ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

២-ចោទប្រកាន់ឈ្មោះ ប៊ិន បញ្ញាធី ភេទប្រុស អាយុ៣៤ឆ្នាំ និង ឈ្មោះ ទស់ ស្រៀវ ហៅ ជ្រា ភេទប្រុស អាយុ៣០ឆ្នាំ ពីបទ ធ្វើមនុស្សឃាតដោយចេតនាគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤-១១ ១៩៩៧ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្ដន្ទាទោស តាមមាត្រា ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១៣ " ច " ចុះថ្ងៃទី ២៣ - ៦ ១៩៩៨ របស់តុលាការក្រុងភ្នំពេញ ដែលមានខ្លឹមសារសេចក្តីសំរេចដូចតទៅ :

១ - ផ្តន្ទាទោសលើឈ្មោះ វស់ ស្រេង ហៅ ជ្រា ដាក់ពន្ធនាគារកំណត់រយៈពេល ១៥ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន ។

- ប៊ុន បញ្ញាធី ដាក់ពន្ធនាគារកំណត់រយៈពេល ១០ឆ្នាំ គិតពីថ្ងៃបានឃុំខ្លួនមក ពីបទធ្វើមនុស្សឃាតដោយចេតនាគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ១៩៩៧ តាមបញ្ញត្តិមាត្រា ៣១ នៃបទបញ្ញត្តិអន្តរកាល ។

២ - ផ្តន្ទាទោសលើឈ្មោះ ទេង សារឿន ហៅ ថៃស្រ៊ុន ដាក់ពន្ធនាគាររយៈពេល ១៣ឆ្នាំ គិតពីថ្ងៃចាប់ឃុំខ្លួនបាន ។ ពីបទសមគំនិត ប្រព្រឹត្តបទមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤ - ១១ ១៩៩៧តាមមាត្រាទី ៦៩ និង មាត្រា ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៣ - អោយឈ្មោះ ជា សុខចេង ហៅ ណាត បានរួចផុតពីការចោទប្រកាន់ទោស ពីបទសមគំនិត ប្រព្រឹត្តអំពើមនុស្សឃាតដោយគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤ - ១១ - ១៩៩៧ ។

៤ - អោយឈ្មោះ ទេង សារឿន ហៅ ថៃស្រ៊ុន , ឈ្មោះ វស់ ស្រេង ហៅ ជ្រា និង ឈ្មោះ ប៊ុន បញ្ញាធី រួមគ្នាសងសំណង និង ជម្ងឺចិត្ត ទៅឈ្មោះ ស្រី ម៉េង ឡុង ជាប្រពន្ធរបស់ឈ្មោះ ម៉ី មឿន សរុបចំនួន ១០ " ដប់ម៉ឺនដុល្លាអាមេរិក " ។ សំណើលើសពីនេះត្រូវបដិសេធចោល ។

៥ - ករណីជនណាទីងរូបត្រូវដាក់គុកបង្ខំលើរូបរាងកាយ ដើម្បីទារប្រាក់ធនទណ្ឌតាមច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយ ក្នុងរឿងព្រហ្មទណ្ឌ ។

៦ - វត្ថុតាងម៉ូតូម៉ាក់សាន់យ៉ាន់មួយគ្រឿងដែលជារបស់ឈ្មោះ ជា សុខចេង ហៅ ណាត ត្រូវប្រគល់អោយឈ្មោះ ជា សុខចេង វិញ ។

- រីឯម៉ូតូម៉ាក់គ្រីស្តាល់ មួយគ្រឿងជាមធ្យោបាយប្រព្រឹត្តបទល្មើសត្រូវរឹបអូសទុកសំរាប់លក់ឡាយឡុងយកប្រាក់សងទៅដើមបណ្តឹងរដ្ឋប្បវេណី ។

៧ - សាលក្រមនេះបានជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ជនជាប់ចោទឈ្មោះ ប៊ុន បញ្ញាធី , ជនជាប់ចោទឈ្មោះ ជា សុខចេង និង កំបាំងមុខជនជាប់ចោទឈ្មោះ ទេង សារឿន ហៅ ថៃស្រ៊ុន , ជនជាប់ចោទឈ្មោះ វស់ ស្រេង ហៅ ជ្រា សំរេចបើកផ្លូវប្តឹងទាស់ និង ប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

- បានឃើញបណ្តឹងឧទ្ធរណ៍ តាមបណ្តឹងលេខ ១២ " ច " ចុះថ្ងៃទី ១៥ - ៧ ១៩៩៨របស់ឈ្មោះ លឹម អួន ប្រពន្ធជនជាប់ចោទឈ្មោះ ទេង សារឿន ប្តឹងពីសាលក្រមនេះលើសេចក្តីសំរេចទាំងមូល ។

- បានឃើញបណ្តឹងឧទ្ធរណ៍ តាមបណ្តឹងលេខ ០៩ " ច " ចុះថ្ងៃទី ១៥ - ៧ ១៩៩៨របស់អ្នកស្រី ម៉េង ឡុង ប្រពន្ធជនរងគ្រោះ ប្តឹងពីសាលក្រមនេះ លើសេចក្តីសំរេចទាំងមូល ។

- បានឃើញ បណ្តឹងឧទ្ធរណ៍ តាមបណ្តឹងលេខ ០៦ " ច " ចុះថ្ងៃទី ២៤ - ៦ ១៩៩៨របស់ព្រះរាជអាជ្ញាតុលាការក្រុងភ្នំពេញ ប្តឹងពីសាលក្រមនេះ ត្រង់ចំណុចទី៣ នៃសេចក្តីសំរេច ។

- បានឃើញ បណ្ដឹងឧទ្ធរណ៍ តាមបណ្ដឹងលេខ ១៣ " ច " ចុះថ្ងៃទី ៣០ - ៧ ១៩៩៨របស់ឈ្មោះ ផា សុខចេង ហៅ ណាត និង ឈ្មោះ ប៊ុន បញ្ញាធី ប្ដឹងពីសាលក្រមនេះ លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញ សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម សាលាឧទ្ធរណ៍ ថា :

. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៣ " ច " ចុះថ្ងៃទី ២៣ - ៦ ១៩៩៨របស់តុលាការក្រុងភ្នំពេញ លើកលែងចំនុចទី២ ត្រូវបដិសេធចោលជាអសារបង់ ។

. អោយឈ្មោះ ទេង សារឿន រួចខ្លួនពីបទចោទ បទលមើសឥតយានជំនិះគ្មានកម្មសិទ្ធិទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤ - ១១ ១៩៩៧ ។

- បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៤៧ ចុះថ្ងៃទី ២៤ - ០២ ១៩៩៩របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារសេចក្ដីសំរេចដូចតទៅ :

១ - ទទួលពាក្យបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាតុលាការក្រុងភ្នំពេញ ចុះថ្ងៃទី ២៤ - ៦ ១៩៩៨ , របស់អ្នកស្រី ម៉េង ឡុង ចុះថ្ងៃទី ១៥ - ៧ ១៩៩៨របស់លោកមេធាវី ជូ ចាន់ធារ៉ា ចុះ - ថ្ងៃទី ២៣ - ៦ ១៩៩៨របស់ឈ្មោះ ងួន លឹមអួន , ផា សុខចេង និងឈ្មោះ ប៊ុន បញ្ញាធី ចុះថ្ងៃទី ៣០ - ៧ - ១៩៩៨ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២ - តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៣ " ច " ចុះថ្ងៃទី ២៣ - ៦ ១៩៩៨របស់តុលាការក្រុងភ្នំពេញ ទុកជាបានការដដែល លើកលែងតែចំនុចទី២ ដែនសេចក្ដីសំរេចត្រូវបដិសេធចោល និង កែប្រែចំណុចទី៤ ដែនសេចក្ដីសំរេចដោយអោយឈ្មោះ ទេង សារឿន ហៅ ថៃស្រ៊ុន រួចផុតពីការទទួលខុសត្រូវលើសំណងជម្ងឺចិត្ត ។ ចំណុចក្រៅពីនេះតម្កល់ទុកជាបានការដដែល ។

៣ - សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ ប៊ុន បញ្ញាធី , ឈ្មោះ អ៊ុក វ៉ាន់ដេត , មេធាវីការពារជនជាប់ចោទ ផា សុខចេង ហៅ មុស្លីណាត និង ជនជាប់ចោទឈ្មោះ ទេង សារឿន ហៅ ថៃស្រ៊ុន , ឈ្មោះ ពីង ធីតា ដើមបណ្ដឹងរដ្ឋប្បវេណី ឈ្មោះ ស្រី ម៉េងឡុង និង មេធាវីការពារដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ជូ ចាន់ធារ៉ា កំបាំងមុខ ឈ្មោះ ទេង សារឿន ហៅ ថៃស្រ៊ុន និង រស់ស្រៀវ ហៅ ជ្រា ។ បើកផ្លូវប្ដឹងទាស់ និង សាទុក្ខតាមកំណត់ច្បាប់ ។

- បានឃើញ បណ្ដឹងសាទុក្ខលើកទី១ លេខ ១៧ ចុះថ្ងៃទី ២៥ - ០២ ១៩៩៩របស់អ្នកស្រី ម៉េង - ឡុង , បណ្ដឹងសាទុក្ខលេខ ២៣ ចុះថ្ងៃទី ២៣ - ៣ ១៩៩៩របស់ឈ្មោះ ប៊ុន បញ្ញាធី និង បណ្ដឹងសាទុក្ខលេខ ៣៧ ចុះថ្ងៃទី ១៨ - ១០ ១៩៩៩របស់ឈ្មោះ រស់ ស្រៀវ ហៅ ជ្រា ប្ដឹងពីសាលដីកានេះលើសេចក្ដីសំរេចទាំងមូល ។

- បានឃើញ សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអម តុលាការកំពូល ថា :

១ - បណ្ដឹងសាទុក្ខរបស់ឈ្មោះ ប៊ុន បញ្ញាធី , ស្រី ម៉េងឡុង និង រស់ ស្រៀវ ហៅជ្រា ស្ថិតក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យ ពិចារណា ។

២ - បដិសេធសាលដីកាព្រហ្មទណ្ឌលេខ ២៦០ ចុះថ្ងៃទី ២២ - ៩ ១៩៩៩របស់សាលាឧទ្ធរណ៍ -

ចោលជាអសារបង់ ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១៩ ចុះថ្ងៃទី ០៥-៦-២០០០ របស់តុលាការកំពូល ដែលវិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទឈ្មោះ វស់ ស្រៀង និង ដើមបណ្តឹងរដ្ឋប្បវេណី អ្នកស្រី ស្រី-ម៉េងឡុង កំបាំងមុខជនជាប់ចោទឈ្មោះ ហេង សារឿន និង ជា សុខចេង ប៉ុន្តែចាត់ទុកជាចំពោះមុខ.

១ - ទទួលបណ្តឹងសាទុក្ខលេខ ១៧ ចុះថ្ងៃទី ២៥-០២-១៩៩៩របស់អ្នកស្រី ស្រី ម៉េងឡុង និង - បណ្តឹងសាទុក្ខលេខ ៣៧ ចុះថ្ងៃទី ១៨-១០-១៩៩៩របស់ឈ្មោះ វស់ ស្រៀវ ហៅ ជ្រា ទុកជាត្រឹមត្រូវ តាមទំរង់ច្បាប់ និង គតិច្បាប់ ។

២ - ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ៤៧ ចុះថ្ងៃទី ២៤-០២-១៩៩៩និង សាលដីកាព្រហ្ម-ទណ្ឌលេខ ២៦០ ចុះថ្ងៃទី ២២-៩-១៩៩៩របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣ - បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ២៤ ចុះថ្ងៃទី ១២-៥-១៩៩៩របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ០៥-៦-២០០០ ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម សាលាឧទ្ធរណ៍ ថា :

វស់ ស្រៀង តុលាការក្រុងភ្នំពេញ សំរេចត្រឹមត្រូវ ទឹថ ស្រ៊ុន តុលាការសំរេចត្រឹមត្រូវ ជា សុខចេង មានធាតុផ្សំគ្រប់គ្រាន់ សំរេចផ្តន្ទាទោស ជា សុខចេង តាមមាត្រា ៣៤ អំពីសំណង ដើមបណ្តឹងរដ្ឋប្បវេណី បានដកបណ្តឹងសុំអោយតុលាការសំរេចតាមច្បាប់ចុះ ។

- បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ១០០ ចុះថ្ងៃទី ០៦-៤-២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារសេចក្តីសំរេចដូចតទៅ :

១ - សំរេចទទួលជំនុំជំរះរឿងក្តីនេះឡើងវិញ តាមអំណាចសាលដីកាលេខ ១៩ ចុះថ្ងៃទី ០៥-៦-២០០០ របស់តុលាការកំពូល ។

២ - សំរេចអោយឈ្មោះ ហេង សារឿន ហៅ ទឹថ ស្រ៊ុន និង ឈ្មោះ ជា សុខចេង ហៅ ណាត រួចខ្លួនពីបទចោទប្រកាន់ក្នុងបទសមគំនិតធ្វើមនុស្សឃាតដោយចេតនាគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤-១១-១៩៩៧ ។

បង្គាប់អោយដោះលែងឈ្មោះ ជា សុខចេង ហៅ ណាត អោយមានសេរីភាពឡើងវិញ កាលបើគ្មានដីកាឃុំខ្លួន ពីបទល្មើសអ្វីផ្សេងទៀត និង បង្គាប់អោយឈប់ស្វែងរកចាប់ខ្លួន ឈ្មោះ ហេង - សារឿន ហៅ ស្រ៊ុន ពីបទ ជាប់ចោទក្នុងបទល្មើស " សមគំនិតធ្វើមនុស្សឃាតដោយចេតនាគិតទុកជាមុន " ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤-១១-១៩៩៧កាលបើឈ្មោះនេះគ្មានដីកាស្វែងរកចាប់ខ្លួនក្នុងបទល្មើសអ្វីផ្សេងទៀត ។

៣ - សំរេចផ្តន្ទាទោសដាក់ពន្ធនាគារឈ្មោះ វស់ ស្រៀង កំណត់ ១២ឆ្នាំ " គិតពីថ្ងៃឃុំខ្លួន ថ្ងៃទី ១៧-៥-១៩៩៩ពីបទធ្វើមនុស្សឃាតដោយចេតនាគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤-១១-១៩៩៧ ។ តាមបញ្ញត្តិមាត្រា ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤ - សំរេចទទួលសំណូមពររបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលឈប់ប្តឹងទាមទារ សោហ៊ុយបង់ខាត

ជម្ងឺចិត្តពីជនជាប់ចោទ ។

៥ - សាលដីកានេះជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ៣០ - ៣ - ២០០១ នៅចំពោះមុខជនជាប់ចោទ និង មេធាវី ការពារមុខដើមបណ្តឹងរដ្ឋប្បវេណី និង ឈ្មោះ ហេង សារឿន ហៅ ស្រ៊ិន និង ប្រកាសជាសាធារណៈ នៅថ្ងៃទី ០៦ - ៤ - ២០០១ ចំពោះមុខមេធាវី ការពារមុខជនជាប់ចោទ និង ដើមបណ្តឹងរដ្ឋប្បវេណី ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញ បណ្តឹងសាទុក្ខលេខ ៣៥ ចុះថ្ងៃទី ១៥ - ៥ - ២០០១ របស់អគ្គព្រះរាជអាជ្ញា អម សាលាឧទ្ធរណ៍ ប្តឹងពីសាលដីកានេះ ត្រង់ចំណុចទី២ នៃសេចក្តីសំរេច ។

- បានឃើញ សារណា ចុះថ្ងៃទី ០៣ - ៨ - ២០០១ របស់ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ធ្វើឡើងតាមកំណត់ច្បាប់ ។

- បានឃើញ សារណាតប ចុះថ្ងៃទី ០៤ - ៩ - ២០០១ របស់ ជា សុខចេង ធ្វើឡើងតាមកំណត់ច្បាប់ ។

- បានឃើញ សារណាតប ចុះថ្ងៃទី ២៧ - ៩ - ២០០១ របស់ ហេង សារឿន ធ្វើឡើងតាមកំណត់ច្បាប់ ។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អម តុលាការកំពូល ថា ៖

ៈ មានពិរុទ្ធភាពលើឈ្មោះ ហេង សារឿន ហៅ ស្រ៊ិន និង ឈ្មោះ ជា សុខចេង ហៅ ណាត ក្នុងបទសមគំនិតធ្វើមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤ - ១១ - ១៩៩៧ ។

ៈ ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ១០០ ចុះថ្ងៃទី ៦ - ៤ - ២០០១ របស់សាលាឧទ្ធរណ៍

ៈ សុំអោយ តុលាការផ្តន្ទាទោស លើឈ្មោះ ហេង សារឿន ហៅ ធីថស្រ៊ិន និង ឈ្មោះ ជា សុខចេង ហៅ មុំ ស៊ីណាត តាមច្បាប់ ។

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់ ឯកឧត្តមអគ្គព្រះរាជអាជ្ញា អម សាលាឧទ្ធរណ៍

- បានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ ជា សុខចេង ថា ៖ តុលាការជាទីគោរពរឿង របស់ខ្ញុំបាទនៅសាលាឧទ្ធរណ៍ បានសំរេចជំរះរួចហើយ តែពុំឃើញមានបណ្តឹងសាទុក្ខរបស់តំណាងមហាអយ្យការ ឡើយ ។ ហេតុនេះប្រសិនបើគ្មានជនរងគ្រោះប្តឹងម្តងរឿងនេះត្រូវចូលស្ងាត់តាំងពីយូរហើយ ។

ម្យ៉ាងទៀតដើមបណ្តឹងរដ្ឋប្បវេណីបានដកពាក្យបណ្តឹងលែងប្តឹង ខ្ញុំបាទតទៅទៀតហើយ ព្រោះគេយល់ថាខ្ញុំបាទមិនមែនជាអ្នកសមគំនិតក្នុងរឿងឃាតកម្មនេះទេ ។ សូមតុលាការកំពូលតំកល់សាលដីការបស់សាលាឧទ្ធរណ៍ ដោយមេត្តា ។

- បានស្តាប់សារណាតបរបស់ជនជាប់ចោទឈ្មោះ ហេង សារឿន

- បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី លោក ខៀវ សុផល ការពារអោយជនជាប់ចោទថា៖ ក្រោយពីបានស្តាប់ការសួរដេញដោល ខ្ញុំបាទសូមធ្វើសេចក្តីសន្និដ្ឋានជូនទាំងអង្គហេតុ និង អង្គច្បាប់ លោក

ព្រះរាជអាជ្ញាបានចោទប្រកាន់កូនក្តីខ្ញុំបាទគ្រាន់តែសង្ស័យចូលទៅលើប្តី ហើយឃុំខ្លួនអស់រយៈពេល៤ខែ ទើបបញ្ជូនទៅជំនុំជំរះ ។

ជារឿងឧក្រិដ្ឋគ្រប់តំណាក់កាលសួរចម្លើយត្រូវធ្វើឡើងចំពោះមុខមេធាវី ប៉ុន្តែពុំមានវត្តមានមេធាវីទេ រាល់ចំលើយមិនស៊ីចង្វាក់គ្នា ចំពោះជនល្មើសឈ្មោះ រស់ ស្រៀង បានឆ្លើយដោយបង្ខិតបង្ខំ គឺពុំបានឆ្លើយដាក់ទៅលើកូនក្តីរបស់ខ្ញុំបាទទេ ។

រាល់ចម្លើយសារភាពបានឆ្លើយខុសគ្នាទាំងអស់ គ្រប់តំណាក់កាលគ្មានមូលដ្ឋានគ្រប់គ្រាន់ទាល់តែសោះ អាស្រ័យហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះពិចារណាតម្កល់សាលដីកាសាលាឧទ្ធរណ៍ ។

- បានស្តាប់តំណាងមហាអយ្យការ ថា ពុំមានអ្វីបន្ថែមទៀតទេ ។
- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់ឯកឧត្តមអគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ចម្លើយរបស់ឈ្មោះ ជា សុខចេង សារណារបស់ឈ្មោះ ហេង សារឿន សេចក្តីសន្និដ្ឋានរបស់មេធាវីជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថាបណ្តឹងសាទុក្ខលេខ ៣៥ ចុះថ្ងៃទី ១៥-៥-២០០១ របស់អគ្គព្រះរាជអាជ្ញាអម សាលាឧទ្ធរណ៍ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះដល់អង្គសេចក្តីបាន តាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី និង មាត្រា ២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចអោយឈ្មោះ ហេង សារឿន ហៅថៃ-ស្រ៊ុន និង ឈ្មោះ ជា សុខចេង ហៅ ណាត រួចខ្លួនពីបទចោទប្រកាន់ក្នុងបទសមគំនិតធ្វើមនុស្សឃាតដោយចេតនា ដោយហេតុថាសាលដីកាសាលាឧទ្ធរណ៍បានសំរេចម្តងហើយនោះ លោកអគ្គព្រះរាជអាជ្ញាមិនបានប្តឹងសាទុក្ខដែរដែលនាំអោយ សាលដីកានោះមានអានុភាពអនុវត្តបានហើយនោះ គឺជាការភ័ន្តច្រឡំពីព្រោះថា : . ពុំមានបទបញ្ញត្តិណាមួយដែល ចែងថាកាលណាអគ្គព្រះរាជអាជ្ញា អម សាលាឧទ្ធរណ៍ ពុំបានប្តឹងសាទុក្ខលើកទី២ ពីសាលដីកាសាលាឧទ្ធរណ៍លើកទី១ របស់សាលាឧទ្ធរណ៍ សាលដីកានេះមានអានុភាពអនុវត្តនោះហើយ ម្យ៉ាងទៀតនេះហើយក្នុងបទអាជ្ញាការឈប់ប្តឹង របស់ដើមបណ្តឹងរដ្ឋប្បវេណី ពុំអាចរំលត់បណ្តឹងអាជ្ញាឡើយ ។

.. ម្យ៉ាងទៀតជនជាប់ចោទ ឈ្មោះ រស់ ស្រៀង ដែលបានឆ្លើយអោយ. ប្រយោជន៍ដល់ជនជាប់ចោទឈ្មោះ ហេង សារឿន ហៅ ថៃ ស្រ៊ុន និង ឈ្មោះ ជា សុខចេង ហៅ មុំ ស៊ីណាត នៅមុខសាលាឧទ្ធរណ៍ ពេលសវនាការលើកទី១ នោះបានឆ្លើយបដិសេធ ចំលើយនេះវិញនៅមុខតុលាការកំពូលដែលបង្ហាញអោយឃើញពីពិរុទ្ធភាពគ្រប់គ្រាន់របស់ជនជាប់ចោទទាំងពីរនាក់ ខាងលើដែលអគ្គព្រះរាជអាជ្ញា

អម សាលាឧទ្ធរណ៍ ត្រូវតែប្ដឹងឈាទុក ។

- យល់ឃើញថា ចម្លើយ របស់ឈ្មោះ ជា សុខចេង ហៅ ណាត នៅចំពោះមុខនគរបាល ចុះថ្ងៃទី ២១ - ១១ ១៩៩៧ចម្លើយរបស់ឈ្មោះ រស់ ស្រេង ហៅ ជ្រា នៅចំពោះមុខនគរបាល ចុះថ្ងៃទី ១៧ - ៥ ១៩៩៨និង នៅចំពោះមុខចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៨ - ៥ ១៩៩៨និង ចម្លើយរបស់ឈ្មោះ ប៊ុន បញ្ញាធី ចុះថ្ងៃទី ២៨ - ១១ ១៩៩៧នៅចំពោះមុខចៅក្រមស៊ើបអង្កេតមានមូលដ្ឋានគ្រប់គ្រាន់ បញ្ជាក់ថា ឈ្មោះ ចេង សារឿន ហៅ ស្រ៊ុន និង ឈ្មោះ ជា សុខចេង ហៅ ណាត ពិតជាបានប្រព្រឹត្ត អំពើសមគំនិតក្នុងបទមនុស្សឃាតគិតទុកជាមុន ប្រព្រឹត្តនៅក្នុងភ្នំពេញ កាលពីថ្ងៃទី ១៤ - ១១ ១៩៩៧ប្រាកដ មែនដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- យល់ឃើញថា ការដែលជនជាប់ចោទឈ្មោះ ជា សុខចេង ហៅ មុំ ស៊ីណាត និង មេធាវី របស់ខ្លួនលើកឡើងនៅពេលសវនាការនេះថា ខ្លួនសុំបដិសេធចម្លើយនៅមុខនគរបាលចោលដោយហេតុ មាន ការធ្វើទារុណកម្មនិងគំរាមកំហែងដែលមានពាក្យបណ្តឹងនិងកំណត់ហេតុរបស់មន្ត្រីលីកាដូជាភស្តុតាងនៅនាតុលាការ កំពូលពុំអាចពិចារណាបានឡើយពីព្រោះពាក្យបណ្តឹងនិងកំណត់ហេតុនេះពុំមែនជាភស្តុតាងគ្រប់គ្រាន់ដែលបញ្ជាក់ ថានគរបាលបានធ្វើទារុណកម្មនិងគំរាមកំហែងទេ ។ម្យ៉ាងទៀតចម្លើយរបស់ជនជាប់ចោទដែលបានឆ្លើយនៅមុខនគរ បាលនោះមានភាពស៊ីសង្វាក់គ្នាជាមួយភស្តុតាងផ្សេងៗជាច្រើនដែលអាចអោយតុលាការជឿបាន ។

- យល់ឃើញថា ការដែលមេធាវីជនជាប់ចោទ ឈ្មោះ ចេង សារឿន និង ជាសុខចេង លើកឡើងនៅពេលសវនាការនេះថា ចម្លើយរបស់ឈ្មោះ រស់ ស្រេង ហៅ ជ្រា ឆ្លើយប្រែប្រួលមិន អាចយកជាភស្តុតាងដាក់បន្ទុកលើ កូនក្តីខ្លួនបាននោះជាការពុំត្រឹមត្រូវទេ ពីព្រោះចម្លើយរបស់ជនជាប់- ចោទ ឈ្មោះ រស់ ស្រេង ហៅ ជ្រា ដែលឆ្លើយនៅមុខនគរបាល នៅមុខចៅក្រមស៊ើបអង្កេត និង នៅ មុខតុលាការកំពូលលើកទី១ មានភាពស៊ីសង្វាក់គ្នា ប៉ុន្តែចម្លើយនៅមុខសាលាឧទ្ធរណ៍ ពេលសវនាការលើកទី១ ជាចម្លើយដែលមិនស៊ីសង្វាក់គ្នាទេ ពិសេសចំលើយដែលថា ឈ្មោះ ចាន់ ជាអ្នកជួលខ្លួនអោយសម្លាប់ជនរងគ្រោះ ពុំមានមូលដ្ឋានដែលអាចអោយជឿបានឡើយ ។ ម្យ៉ាងទៀតជនជាប់ចោទឈ្មោះនេះក៏បានឆ្លើយបដិសេធ ចំលើយនៅ សាលាឧទ្ធរណ៍ នៅមុខតុលាការកំពូលពេលសវនាការលើកទី១រួចហើយដែរ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចអោយជនជាប់ចោទឈ្មោះ ចេង សារឿន ហៅ វិចស្រ៊ុន រួចខ្លួនពីបទចោទដែលតុលាការក្រុងភ្នំពេញបានសំរេចផ្តន្ទាទោស ១៣ឆ្នាំ តាមបណ្តឹងឧទ្ធរណ៍ របស់ឈ្មោះ ងួន លីមអួន ជាប្រពន្ធនោះ គឺជាការរំលោភលើមាត្រា ១៦២ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

- យល់ឃើញថា ពុំមានភស្តុតាងផ្សេងណាដែលបញ្ជាក់ថាជនជាប់ចោទឈ្មោះ រស់ ស្រេង និង ឈ្មោះ ប៊ុន បញ្ញាធី ទៅសម្លាប់ជនរងគ្រោះឈ្មោះ ម៉ី មឿន ដោយពុំមានការជួលពីឈ្មោះ ចេង- សារឿន ហៅ វិចស្រ៊ុន និង ឈ្មោះ ជា សុខចេង ហៅ មុំ ស៊ីណាត ទេ ។

- យល់ឃើញថា ឈ្មោះ ចេង សារឿន បានធ្វើសារណាការពាររឿងក្តីរបស់ខ្លួនជូនមក តុលាការកំពូលរួចហើយ ហើយមេធាវីរបស់ឈ្មោះ នេះក៏បានមកចូលរួមសវនាការនេះហើយ ដូច្នេះតុលាការ កំពូលជំនុំជំរះរឿងនេះកំបាំងមុខឈ្មោះនេះ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១០០ ចុះថ្ងៃទី ០៦ - ៤ - ២០០១ របស់សាលាឧទ្ធរណ៍

ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ លើកលែងតែចំណុចទី២ ដែលត្រូវទុកជាមោឃៈ និង សំរេចជាថ្មី ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទ ឈ្មោះ ជា សុខចេង កំបាំងមុខជនជាប់ចោទ ឈ្មោះ ហេង សារឿន ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

១ - ទទួលបណ្តឹងសាទុក្ខលេខ ៣៥ ចុះថ្ងៃទី ១៥ - ៥ - ២០០១ របស់អគ្គព្រះរាជអាជ្ញា អម សាលាឧទ្ធរណ៍ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - តំកល់សាលដីកាព្រហ្មទណ្ឌលេខ ១០០ ចុះថ្ងៃទី ០៦ - ៤ - ២០០១ របស់សាលាឧទ្ធរណ៍ ទុកជាបានការលើកលែងតែចំណុចទី២ ដែលត្រូវទុកជាមោឃៈ និង សំរេចជាថ្មី ។

៣ - ផ្តន្ទាទោស ឈ្មោះ ហេង សារឿន ហៅ ទឹថស្រ៊ុន ដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ គិតពីថ្ងៃចាប់ខ្លួនបាន និង ឈ្មោះ ជា សុខចេង ហៅ មុំ ស៊ីណាត ដាក់ពន្ធនាគារកំណត់ ១៣ឆ្នាំ គិតពីថ្ងៃឃុំខ្លួន ពីបទសមគនិតក្នុងអំពើមនុស្សឃាដគិតទុកជាមុន ប្រព្រឹត្តនៅក្រុងភ្នំពេញ កាលពីថ្ងៃទី ១៤ - ១១ - ១៩៩៧ តាម មាត្រា ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

៤ - បង្គាប់អោយស្វែងរកចាប់ខ្លួនឈ្មោះ ហេង សារឿន ហៅ ទឹថស្រ៊ុន មកឃុំឃាំងនៅ ពន្ធនាគារ ។

៥ - សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ - ២០០២ ។